បន្ទាប់ពីបានពិចារណាលើហេតុផលគ្រប់ជ្រុងជ្រោយ និងបន្ទាប់ពីបានពិចារណាលើច្បាប់ជាធរមាន អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស កាំង ហ្កេកអ៊ាវ ដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ឆ្នាំ។ អង្គជំនុំជម្រះកាត់បន្ថយទោសពីរយៈពេលផ្តន្ទាទោសខាងលើចំនួន ៥ឆ្នាំ ដោយសារតែការរំលោភលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ក្នុងអំឡុងពេលឃុំខ្លួនខុសនីតិវិធីច្បាប់ ដោយតុលាការយោធា ពីខែឧសភា ឆ្នាំ១៩៩៩ ដល់ខែកក្កដា ឆ្នាំ២០០៧ (ជាងប្រាំបីឆ្នាំ)។ រយៈពេលដែល កាំង ហ្កេកអ៊ាវ ត្រូវបានឃុំខ្លួនចាប់ពី ខែឧសភា ឆ្នាំ១៩៩៩ មកនោះ នឹងបូកបញ្ចូលនៅក្នុងរយៈពេលនៃទោសជាប់ពន្ធនាគារ ចំនួន ៣០ឆ្នាំ។ នេះមានន័យថា កាំង ហ្កេកអ៊ាវ ត្រូវជាប់ក្នុងពន្ធនាគារសរុបចំនួន ៣០ឆ្នាំ ដោយគិតពីឆ្នាំ១៩៩៩មក។




**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ផ្លូវជាតិលេខ ៤ ស/ក ចោមចៅ ខណ្ឌ ដង្កោ

ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ ០ ២៣ ២១៩ ៨១៤

ទូរសារ ០ ២៣ ២១៩ ៨៤១

www.eccc.gov.kh

www.facebook.com/krtribunal
www.twitter.com/krtribunal
www.flickr.com/photos/krtribunal
www.youtube.com/krtribunal




## សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង

ប្រកាសនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០

# សំណុំរឿង ០០១

# កាំង ហ្កេកអ៊ាវ ហៅ ឌុច

ឯកសារនេះត្រូវបានរៀបចំឡើង ដើម្បីជាជំនួយដល់ប្រជាជនសាមញ្ញ ឲ្យបានយល់ពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងសម្រេចលើសំណុំរឿងប្រឆាំងឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច។ ឯកសារនេះមិនមែនជាឯកសារផ្លូវការទេ ហើយក៏មិនមែនជាការបកស្រាយផ្លូវច្បាប់ទៅលើសាលក្រមនេះដែរ។ ដើម្បីយល់ឲ្យបានច្បាស់ទៅលើសាលក្រមនេះ សូមអានសាលក្រមផ្លូវការដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង។ សូមទាក់ទងការិយាល័យ ឃុំ/សង្កាត់ ឬ ស្រុក/ខណ្ឌ ដែលនៅជិតអ្នកបំផុត ដើម្បីអានច្បាប់ចម្លងនៃសាលក្រមពេញលេញ។

## សាលក្រមលើសំណុំរឿង ០០១ ប្រឆាំងឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញសាលក្រមរបស់ខ្លួននៅក្នុងការជំនុំជម្រះក្តីជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ។

អ.វ.ត.ក អាចកាត់សេចក្តីតែទៅលើបុគ្គលពីរប្រភេទតែប៉ុណ្ណោះ៖

ក. មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ

ខ. អ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កាំង ហ្គេកអ៊ាវ មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ដោយផ្អែកលើនិយមន័យដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា គាត់គឺជាបុគ្គលដែលស្ថិតនៅក្នុងប្រភេទ “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ក្នុងឋានៈជាអនុប្រធាន ហើយក្រោយមកជាប្រធានមន្ទីរសន្តិសុខ ស-២១ នៅទីក្រុងភ្នំពេញ កាំង ហ្គេកអ៊ាវ ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះមរណភាពរបស់ប្រជាជនកម្ពុជា យ៉ាងហោចណាស់ចំនួន ១២.២៧២ នាក់។ គាត់ក៏ត្រូវបានរកឃើញថា ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅ ស-២៤ ផងដែរ។

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កាំង ហ្គេកអ៊ាវ មានពិរុទ្ធភាពចំពោះ៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) ដោយរួមបញ្ចូលទាំងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្មនិងការរំលោភលើផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ខែសីហាឆ្នាំ១៩៤៩ (ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់ រាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិល នូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់)។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង សម្រេចថាតើទោសប្រភេទណាដែលត្រូវផ្តន្ទាចំពោះ កាំង ហ្គេកអ៊ាវ នោះ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានពិចារណាទៅលើកត្តានានា ដែលអាចធ្វើយុត្តិកម្មចំពោះស្ថានទម្ងន់ទោស និងទាំងស្ថានសម្រាលទោស។

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កត្តាមួយចំនួនដែលអាចធ្វើយុត្តិកម្មសម្រាប់ស្ថានទម្ងន់ទោស នោះគឺ៖

- ការបំពានលើសិទ្ធិអំណាច ឬមុខនាទីជាផ្លូវការរបស់ជនជាប់ចោទ
- ភាពឃោរឃៅព្រៃផ្សៃនៃឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្ត
- ចំនួនជនរងគ្រោះច្រើន ដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត។
- ភាពគ្មានទីពឹងនៃជនរងគ្រោះ
- ចេតនារើសអើងដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម

ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កត្តាខាងក្រោមនេះ អាចធ្វើយុត្តិកម្មសម្រាប់ស្ថានសម្រាលទោសបាន៖

- កិច្ចសហការរបស់ កាំង ហ្គេកអ៊ាវ ជាមួយនឹង អ.វ.ត.ក ដោយគាត់បានផ្តល់ព័ត៌មានសំខាន់ៗ អំពីតួនាទីរបស់គាត់នៅក្នុងប្រតិបត្តិការរបស់ ស-២១។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា កិច្ចសហការរបស់គាត់ បានជួយដល់ការស្វែងរកការផ្សះផ្សារជាតិ
- បរិយាកាសបង្ខិតបង្ខំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងមុខតំណែងក្រោមឱវាទគេ របស់ កាំង ហ្គេកអ៊ាវ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា
- ការសម្តែងនូវវិប្បដិសារី របស់ កាំង ហ្គេកអ៊ាវ បើទោះជាមានកម្រិតក្តី
- លទ្ធភាពដែលអាចស្តារនីតិសម្បទាឡើងវិញបាន

មុននឹងធ្វើការសម្រេច ថាតើទោសកម្រិតណាត្រូវផ្តន្ទាលើជនជាប់ចោទនោះ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានពិចារណា លើហេតុផលគ្រប់ជ្រុងជ្រោយទាំងអស់នៃរឿងក្តីនេះ។ ហេតុផលទាំងនេះ រួមបញ្ចូលទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ស្ថានទម្ងន់ទោសនិងស្ថានសម្រាលទោស ការវាយតម្លៃទៅលើស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទ និងសក្ខីកម្មរបស់សាក្សីដែលបានផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាផងដែរ លើគោលការណ៍នៃការផ្តន្ទាទោសនៅតុលាការអន្តរជាតិនានា ដែលធ្លាប់ដោះស្រាយសំណុំរឿងពាក់ព័ន្ធ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។